ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល　　　ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងព្រហ្មទណ្ឌ　　　នាមនាមប្រជារាស្ត្រខ្មែរ

លេខ : ៨១　　　តុលាការកំពូល

ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៤

សាលដីកា　　　បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ២៣ ខែ មីនា

លេខ : ១៦　　　ឆ្នាំ២០០៥ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ :

ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០០៥

| | | |
|---|---|---|
| ១- ឯកឧត្តម | ឃឹម ប៉ុណ្ណ | ប្រធាន |
| ២- លោក | ឈឹម ស៊ីផល | ចៅក្រម |
| ៣- លោក | ប្រាក់ គីមសាន | ចៅក្រម |
| ៤- លោក | យស់ សូខឿន | ចៅក្រម |
| ៥- លោក | សោម សិរីវឌ្ឍ | ចៅក្រម-របាយការណ៍ |

ក្រឡាបញ្ជី

លោកស្រី ថូ ណារី

តំណាងមហាអយ្យការ

លោក ឈួន ចន្ថា ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាព្រហ្មទណ្ឌលេខ៨២"ច" ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ និង សំណុំរឿងព្រហ្មទណ្ឌលេខ៨១ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៤ របស់តុលាការកំពូល ។

***ចំពោះ*** : រំលោភលើសិទ្ធិអ្នកនិពន្ធ និង សិទ្ធិប្រហាក់ប្រហែល ប្រព្រឹត្តនៅផ្សារកំពង់ធំ ឃុំកំពង់ធំ ស្រុកស្ទឹងសែន ខេត្តកំពង់ធំកាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៣បទល្មើសដែលមានចែងអោយផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៦៤ នៃច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និង សិទ្ធិប្រហាក់ប្រហែល ។

-ជនជាប់ចោទឈ្មោះលីន នី (ចុងបណ្តឹងសាទុក្ខ) ភេទស្រី អាយុ២៤ឆ្នាំ ជាតិខ្មែរ មុខរបរលក់កាសែត ទីកន្លែងកំណើត កើតនៅភូមិកំពុងត្របែក ឃុំសណ្តាន់ ស្រុកសណ្តាន់ ខេត្តកំពង់ធំ ទីលំនៅបច្ចុប្បន្ន ភូមិដីរជាន់ខ្លា ឃុំដីរជាន់ខ្លា ស្រុកស្ទឹងសែន ខេត្តកំពង់ធំ ។ ឪពុកឈ្មោះអៀង ផេង "រស់" ម្តាយឈ្មោះណៃ ឈីន "រស់" ប្តីឈ្មោះជួន តា មានកូន០២នាក់ ។ ក្រៅឃុំ ។ មេធាវី : គ្មាន

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះឡាយ សុកហុក ភេទប្រុស អាយុ៤៥ឆ្នាំ ជាតិខ្មែរ មុខរបរនាយកក្រុមហ៊ុនផលិតកម្ម SANDAY VIDEO មានទីលំនៅផ្ទះលេខ៧៥E₀ ផ្លូវព្រះសីហនុ សង្កាត់ចតុមុខ

ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ ។

- មានមេធាវី : លោក វណ្ណ ផលណា

តាមពាក្យបណ្តឹង ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៣ របស់ឈ្មោះឡាយ សុកហុក បានបញ្ជាក់ថា ខ្លួនប្តឹងពីឈ្មោះលីន នី ពីបទ : ផលិតលួចលក់ដូល និង ស្តុកទុកនូវ CD ,VCD ដាក់តាំងលក់ផលិតផលក្លែងក្លាយរបស់ក្រុមហ៊ុន SUNDAY ដាក់តាំងលក់ចែកចាយជាសាធារណៈ បានធ្វើអោយប៉ះពាល់ដល់ផលប្រយោជន៍របស់ក្រុមហ៊ុនខ្លួនយ៉ាងធ្ងន់ធ្ងរ និង អន្តរាយអស់ប្រាក់ជាច្រើន ។ ខ្លួនសំណូមពរទាមទារប្រាក់ដែលខាតបង់ចំនួន៥០.០០០ដុល្លា សុំទាមទារជម្ងឺចិត្តចំនួន១០.០០០ដុល្លា និង សុំផ្តន្ទាទោសជនល្មើសតាមច្បាប់ ។

តាមចំលើយរបស់ឈ្មោះលីន នី ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៣ នៅមុខព្រះរាជអាជ្ញា ថាខ្លួនបានដាក់លក់ផលិតផល វីស៊ីឌី ដែលខ្លួន បានទិញពីភ្នំពេញមក ខ្លួនមិនស្គាល់ម្ចាស់ហាងលក់ទេ ។ សមត្ថកិច្ចបានមកដកហូតសំភារៈរបស់ខ្លួនអស់ ចំនួន១១៧ VCD ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ អមតុលាការខេត្តកំពង់ធំថា : បានសំរេចចោទប្រកាន់លើឈ្មោះលីន នី ភេទស្រី អាយុ២៤ឆ្នាំ ជាតិខ្មែរ មានទីលំនៅភូមិដីរជាន់ខ្លា ឃុំដីរជាន់ខ្លា ស្រុកស្ទឹងសែន ខេត្តកំពង់ធំ ។ ពីបទ : រំលោភលើសិទ្ធិអ្នកនិពន្ធ និង សិទ្ធប្រហាក់ប្រហែល ប្រព្រឹត្តនៅផ្សារកំពង់ធំ ឃុំកំពង់ធំ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ កាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៣ តាមដីកាលេខ៩១៦ អក ២០០៣ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៣ ។

-បានឃើញដីកាឃុំខ្លួនលើឈ្មោះលីន នី ភេទស្រី អាយុ២៤ឆ្នាំ មុខរបរលក់ VCD តាមដីកាលេខ២៥២ ឃ.ខ.០៣ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៣ របស់ចៅក្រមស៊ើបអង្កេតតុលាការខេត្តកំពង់ធំ ។

-បានឃើញលិខិតសុំធានាអោយឈ្មោះលីន នី បាននៅក្រៅឃុំ របស់ឈ្មោះដួន គា ភេទប្រុស អាយុ៣០ឆ្នាំ ជាសាស្ត្រាចារ្យ ដែលត្រូវជាប្តីរបស់ជនជាប់ចោទឈ្មោះលីន នី ។

-បានឃើញដីកាសំរេចលេខ១៨២៣/០៣ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៣ របស់ចៅក្រមស៊ើបអង្កេតតុលាការខេត្តកំពង់ធំ ដោយសំរេចឱ្យជនល្មើសនៅក្រៅឃុំជាបណ្តោះអាសន្ន ។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ៤៩ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០០៣ របស់លោកឈុន លឹមខនព្រះរាជអាជ្ញារង អមតុលាការខេត្តកំពង់ធំ ប្តឹងមិនសុខចិត្តនឹងដីកាសំរេចលេខ១៨២៣/០៣ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៣ របស់ចៅក្រមស៊ើបអង្កេតតុលាការខេត្តកំពង់ធំ ត្រង់ចំណុចឱ្យជនល្មើសឈ្មោះលីន នី នៅក្រៅឃុំជាបណ្តោះអាសន្ន ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ថា :

១-ទទួលបណ្តឹងឧទ្ធរណ៍ របស់ព្រះរាជអាជ្ញា ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០០៣ ត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-បដិសេធដីកាលេខ១៨២៣ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៣ ចោលជាអសារបង់ ព្រមទាំងអោយសាលាឧទ្ធរណ៍ ចាត់ការតាមច្បាប់ ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ៨២"ច" ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែលបានសំរេច :

១-ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០០៣ របស់លោកព្រះរាជ-អាជ្ញារង អមតុលាការខេត្តកំពង់ធំ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោល ដោយទាស់និងគតិច្បាប់ ។

២-តំកល់ដីកាសំរេចអោយជនល្មើសនៅក្រៅឃុំជាបណ្ដោះអាសន្នលេខ១៨២៣ ព្រ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៣ របស់ចៅក្រមស៊ើបអង្កេត តុលាការខេត្តកំពង់ធំ ទុកជាបានការដដែល ។

៣-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខមេធាវីការពារដើមបណ្ដឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទ និង ដើមបណ្ដឹងរដ្ឋប្បវេណី បើកផ្លូវប្ដឹងតវ៉ាតាមកំណត់ច្បាប់ ។

-បានឃើញបណ្ដឹងសាទុក្ខលេខ០៣ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០០៤ របស់ឯកឧត្ដម អគ្គព្រះរាជអាជ្ញា សាលាឧទ្ធរណ៍ ប្ដឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ៨២"ច" ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចសំរេចតម្កល់ដីកាសំរេចរបស់ចៅក្រមស៊ើបអង្កេតលេខ១៨២៣ព្រ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៣ ដែលជាដីកាសម្រេចខុសច្បាប់នីតិវិធី ។

-បានឃើញសារណាលេខ៤៣៥/០៣ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៣ របស់អគ្គព្រះរាជអាជ្ញា សាលាឧទ្ធរណ៍ ធ្វើឡើងតាមកំណត់ច្បាប់ ។

-បានឃើញសារណាតប ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៤ របស់ឈ្មោះលីន នី ធ្វើឡើងតាមកំណត់ច្បាប់ ។

- បានស្ដាប់ចៅក្រមរបាយការណ៍ អានរបាយការណ៍

-បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូល ថា : បើផ្អែកតាមរបាយការណ៍របស់ព្រះរាជអាជ្ញាអមតុលាការខេត្តកំពង់ធំ ផ្ញើរជូនមកអគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍ ឃើញថា ចៅក្រមអង្កេតតុលាការកំពង់ធំ បានចេញដីកាឃុំខ្លួនឈ្មោះលីន នី តែតាមពិតពុំបានឃុំខ្លួនជនជាប់ចោទទេ ហើយស្រាប់តែសាលាឧទ្ធរណ៍ សំរេចតម្កល់ដីកាសំរេចរបស់តុលាការកំពង់ធំ ដូច្នេះ សាលដីការបស់សាលាឧទ្ធរណ៍ សំរេចដោយបំពានច្បាប់ ។ សូមក្រុមប្រឹក្សាជំនុំជំរះ ពិនិត្យ និង សំរេចតាមច្បាប់ ។

-បានស្ដាប់ក្រឡាបញ្ជីអានសារណា របស់អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ( ម្ចាស់បណ្ដឹងសាទុក្ខ) នៅពេលជំនុំជំរះ ។

-បានស្ដាប់ក្រឡាបញ្ជីអានសារណា របស់ឈ្មោះលីន នី ( ជាចុងបណ្ដឹងសាទុក្ខ) នៅពេលជំនុំជំរះ ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកវណ្ណ ផលណា ជាមេធាវីការពារឱ្យឈ្មោះឡាយ សុកហុក នៅពេលជំនុំជំរះថា : ក្រោយពីបានស្តាប់ចំលើយដោះសារក្នុងសារណារបស់ឈ្មោះលីន ទី ឃើញថា ចំលើយនេះពុំសមហេតុផល ឡើយ ក្រុមហ៊ុនកូនក្តីខ្ញុំបាទឈ្មោះ SUNDAY VIDEO (សាន់ដេវិដេអូ) ជាក្រុមហ៊ុនដែលបានចុះក្នុង បញ្ជីពាណិជ្ជកម្មរបស់ក្រសួងវប្បធម៌ត្រឹមត្រូវ ក្រោយប្រកាសរបស់ក្រសួងវប្បធម៌ ក្រុមហ៊ុននេះបានចេញលក់នូវផលិតផល (CD VCD ) ស៊ីឌី និង វីស៊ីឌី ចំរៀងដោយធ្វើចរាចរទូទាំងប្រទេស ។ ក្រោយពីបានទទួលដំណឹងថា មានគេលួចថតចំលងផលិតផលរបស់ខ្លួននៅផ្សារកំពង់ធំ កូនក្តីខ្ញុំបាទប្តឹងទៅតុលាការខេត្តកំពង់ធំ ហើយបានចុះឆែកឆេរ និង រឹបអូសបាននូវឌីសចំនួន១២០ដុំ ដែលជាឌីសលួចចំលងនៅតូបរបស់ឈ្មោះលីន ទី ហើយឈ្មោះលីន ទី នេះក៏បានឆ្លើយទទួលស្គាល់ដែរ ដែលធ្វើឱ្យក្រុមហ៊ុនសាន់ដេ វីដេអូ មានការខាតបង់លុយកាក់យ៉ាងច្រើន ព្រោះថា មុននឹងផលិតចេញជាស៊ីឌី វីស៊ីឌី កូនក្តីខ្ញុំបាទត្រូវចំណាយអស់ប្រាក់រាប់ម៉ឺនដុល្លា ។ ដូច្នេះខ្ញុំបាទសូមសំណូមពរដល់ក្រុមប្រឹក្សាជំនុំជំរះតុលាការកំពូល មេត្តាបដិសេធសាលដីកាសាលាឧទ្ធរណ៍ចោលជាអសារបង់ ។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការ អមតុលាការកំពូល នៅពេលជំនុំជំរះថា : ពុំមានយោបល់អ្វីបន្ថែមទៀតទេ

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់អគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍ និង សេចក្តីសន្និដ្ឋានការពាររបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ។

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ០៣ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០០៤ របស់អគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបាន ដោយយោងតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចតម្កល់ដីកាសំរេចឱ្យជនជាប់ចោទនៅក្រៅឃុំជាបណ្តោះអាសន្ននោះ គឺជាការភ័ន្តច្រឡំ ពីព្រោះថា តុលាការខេត្តកំពង់ធំពុំទាន់ជំនុំជំរះដីកាសំរេចលេខ ២៥២ ឃ.ខ.០៣ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៣ នៅឡើយ ។

-យល់ឃើញថា ជនជាប់ចោទបានធ្វើសារណាការពារជូនមកតុលាការកំពូលហើយ ប៉ុន្តែពុំបានចូលរួមសវនាការនេះទេ រួមទាំងដើមបណ្តឹងរដ្ឋប្បវេណី ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះកំបាំងមុខជនជាប់ចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ៨៤២"ច" ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ បានលក្ខណៈខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

## ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តីចំពោះមុខមេធាវី ដើមបណ្តឹងរដ្ឋប្បវេណី

កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី និង ជនជាប់ចោទ ប៉ុន្តែចាត់ទុកជាចំពោះមុខ

១-ទទួលបណ្តឹងសាទុក្ខលេខ០៣ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៤ របស់អគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-ទុកជាមោឃៈសាលដីកាព្រហ្មទណ្ឌលេខ៨៤២"ច" ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ពេញទាំងមូល ។

៣-បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ៨១ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៤ របស់តុលាការកំពូលទៅតុលាការខេត្តកំពង់ធំ ដើម្បីចាត់ការរឿងអង្គសេចក្តី ។

៤-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០០៥ ។